ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិគាំពារសង្គម
លេខ:....✓.....ក.ជ.គ.ស.........

*ថ្ងៃ អង្គារ ១០ រោច ខែ អាសាឍ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី១២

នៅព្រឹកថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២៤, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី ១២ ដោយមានការចូលរួមពី **ឯកឧត្តម លោកជំទាវ** ដែលជាអនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ព្រមទាំងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## ១. សម្រាប់សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការផ្តល់អាហារតាមសាលារៀន

ស្របតាមការចង្អុលបង្ហាញរបស់ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ ***"សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការផ្តល់អាហារតាមសាលារៀនឆ្នាំ ២០២៤-២០៣៥"*** ដែលជាឯកសារកម្រិតគោលនយោបាយដើម្បីសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ សុខភាព និងការអប់រំកុមារ ព្រមទាំងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងយកចិត្តទុកដាក់លើចំណុចសំខាន់ៗ និងបានផ្តល់មតិយោបល់កែសម្រួលដើម្បីឱ្យ ***"សេចក្តីព្រាងគោលនយោបាយ"*** នេះ កាន់តែមានភាពពេញលេញ និងសង្គតិភាព មុននឹងដាក់សេចក្តីព្រាងនេះ គោរពសុំការអនុម័តដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល នាពេលខាងមុខ ។

## ២. របាយការណ៍បិទបញ្ចប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមរបស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បានដាក់ឱ្យអនុវត្ត ***"កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩"*** នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០២០។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
nspc.gov.kh / t.me/socialprotectionkh
ទូរសព្ទលេខ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone : (+855) 23 890 666
gs_nspc@mef.gov.kh

*"ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់"* នេះ មានរយៈពេល **៤៦ ខែ** ដែលក្នុងនោះការអនុវត្តពេញលេញរយៈពេល **៤៣ ខែ** (ខែមិថុនា ឆ្នាំ ២០២០ ដល់ ខែធ្នូ ឆ្នាំ ២០២៣) និងការអនុវត្តយុទ្ធសាស្ត្រចាកចេញពីកម្មវិធីមានរយៈពេល **៣ ខែ** (ខែ មករា ដល់ខែ មីនា ឆ្នាំ ២០២៤) ដោយបានផ្តល់សាច់ប្រាក់ឧបត្ថម្ភប្រចាំខែដល់គ្រួសារក្រីក្រ និងងាយរងគ្រោះចំនួនប្រមាណ **៧០ ម៉ឺនគ្រួសារ** ស្មើនឹង **២,៨ លាននាក់** ដោយបានចំណាយថវិការផ្ទសរុបចំនួន **៥ ៤៣៨ ៤៨៦ ៤១៩ ០០០ រៀល** ឬស្មើនឹង **១ ៣៥៩,៦២ លានដុល្លារអាម៉េរិក** ។

កន្លងមក, ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងប្រតិតុល្យការនៃការអនុវត្តកម្មវិធី ក្រុមប្រឹក្សាជាតិគាំពារសង្គម បានរៀបចំការវាយតម្លៃជាប្រចាំសម្រាប់ *"កម្មវិធីឧបត្ថម្ភសាច់ប្រាក់"* នេះ រួមមានទាំងការវាយតម្លៃកម្មវិបាករបស់កម្មវិធីលើសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន និងការវាយតម្លៃលើដំណើរការនៃការអនុវត្តកម្មវិធីផងដែរ។ ក្រោយពីបានបិទបញ្ចប់ការអនុវត្ត *"កម្មវិធីឧបត្ថម្ភសាច់ប្រាក់"* នេះ រាជរដ្ឋាភិបាល ក៏បានសម្រេចដាក់ឱ្យអនុវត្ត *"កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ"* តាមរយៈការធ្វើស្ថាប័នូបនីយកម្ម និងសមាហរណកម្មកម្មវិធីជាតិជំនួយសង្គមទាំងអស់ ដើម្បីពង្រីកការគ្របដណ្តប់ បង្កើនប្រសិទ្ធភាព និងការវិនិយោគហិរញ្ញវត្ថុ ជាមួយនឹងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនេះ ដូចខាងក្រោម៖

គិតត្រឹមដំណាច់ ខែមិថុនា ឆ្នាំ ២០២៤នេះ, ក្នុងចំណោមគ្រួសារគោលដៅដែលមានបណ្តុំសមធម៌ចំនួន **៧០ ម៉ឺនគ្រួសារ** ឬស្មើនឹង **២,៨ លាននាក់** មានគ្រួសារចំនួន **៥៧ ម៉ឺនគ្រួសារ** (ប្រមាណ ៨៤ %) បានចុះឈ្មោះចូលកម្មវិធីរួចរាល់ និងទទួលផលពីកម្មវិធី ដោយរាជរដ្ឋាភិបាលបានចំណាយថវិកាសរុប ប្រមាណ **៧២,៥ ប៊ីលានរៀល (ប្រមាណ ១៨ លានដុល្លារអាម៉េរិក)**។

ដោយឡែក សម្រាប់ក្រុមគោលដៅនៅសេសសល់ចំនួនប្រមាណ ១៦%, ក្រុមការងារអន្តរក្រសួងពាក់ព័ន្ធ ដោយមានការសម្របសម្រួលពី អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បាន និងកំពុងរៀបចំយុទ្ធនាការដើម្បីជំរុញការចុះបញ្ជីឱ្យបានទាន់ពេល ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ។

**ក្រុមប្រឹក្សាជាតិគាំពារសង្គម**